## រយៈពេល និងសកម្មភាពនៃគម្រោង

### ដំណាក់កាលនិយមន័យ ១៨ ខែ

ដំណាក់កាលនិយមន័យ មានគោលបំណងបង្រួបបង្រួមរចនាសម្ព័ន្ធថភាពជាដៃគូរស្រាវជ្រាវ អនុវត្ត និងផ្សព្វផ្សាយក្នុងស្រុករបស់ពួកយើង។ នៅកម្រិតស្រាវជ្រាវគោលដៅសំខាន់ៗ គឺការធ្វើការរួមគ្នាលើការកំណត់សូចនាករ/វិធីសាស្ត្រពាក់ព័ន្ធ។ ទាំងនេះ នឹងបង្ហាញអំពីការគោរពចំណេះដឹងគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវគុណភាពនៃជីវិតនៃការរស់នៅក្នុងទីក្រុង។ លទ្ធផលនៃការស្រាវជ្រាវ ត្រូវបានសង្ខេបក្នុងរបាយការណ៍មូលដ្ឋាននៃកញ្ចប់ការងារនីមួយៗ។ សម្រាប់ដៃគូរអនុវត្តរបស់ពួកយើង របាយការណ៍សង្ខេបទាំងនេះ ផ្តល់ព័ត៌មានជាមូលដ្ឋានដំបូងសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដោយពឹងផ្អែកលើភស្តុតាង។ ការសិក្សាសមិទ្ធលទ្ធភាពសម្រាប់គម្រោងសាកល្បងគំរូទីក្រុង គួរប្រមូលលទ្ធផលនៃការស្រាវជ្រាវរបស់ពួកយើងតាមរបៀបអន្តរវិស័យ។
អន្តរវិស័យ បានបង្កើតផលិតផល Build4People ដូចជាការតាំងពីព័រណ៌លើកទី១ «អគារបៃតង និងអ្នកជិតខាងទីក្រុងប្រកបដោយនិរន្តរភាព»ឬលទ្ធផលនៃការស្ទង់មតិរបស់យើងអំពីគុណភាពនៃជីវិតទីក្រុង នឹងត្រូវបានបង្ហាញនៅក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយជាច្រើន។
ស្របទៅនឹងសកម្មភាពទាំងអស់ នឹងមានសកម្មភាពទំនាក់ទំនងសាធារណៈភាគច្រើនតាមរយៈបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម

### ដំណាក់កាលស្រាវជ្រាវ &អភិវឌ្ឍន៍ ( 2 x 24 ខែ )

នៅពេលចាប់ផ្តើមដំណាក់កាលស្រាវជ្រាវ និងអភិវឌ្ឍន៍រយៈពេល ៤ឆ្នាំ យើងនឹងស្រាវជ្រាវព័ត៌មានលម្អិតអំពីលក្ខខណ្ឌក្នុងស្រុក ដើម្បីបង្កើតមូលដ្ឋានត្រឹមត្រូវសម្រាប់សេចក្តីសម្រេចចិត្តដោយពឹងផ្អែកលើភស្តុតាង។ ការធ្វើបែបនេះ នឹងផ្តល់ព័ត៌មានជាឯកសារយោងនិងធនធានសម្រាប់អាជ្ញាធរក្រុង និងជាតិពាក់ព័ន្ធ ឧស្សាហកម្មក្នុងស្រុក និងសម្រាប់ការប្រើប្រាស់ដោយសាធារណៈជនទូទៅ។ ឧបករណ៍ និងធនធានរួមមានសៀវភៅណែនាំសម្រាប់លំនៅឋានបៃតងដែលជាជាសន្ទស្សន៍ច្នៃប្រឌិតថ្មីនៃគុណភាពជីវិតនៃជីវិតទីក្រុង គម្រោងបង្ហាញជាច្រើនព្រមទាំងវិធានការពង្រឹងសមត្ថភាពនៅសាកលវិទ្យាល័យ និងក្នុងចំណោមអ្នកអនុវត្ត លើសពីនេះ ការសិក្សាសមិទ្ធលទ្ធភាពជាច្រើន នឹងត្រូវធ្វើឡើងដើម្បីរៀបចំដាក់បញ្ចូលក្រុមហ៊ុន និងអង្គការម្ចាស់ជំនួយទៅក្នុងដំណាក់កាលអនុវត្តជាបន្តបន្ទាប់។

### ដំណាក់កាលអនុវត្ត ( 24 ខែ )

ដំណាក់កាលនេះ មានគោលបំណងលើកទឹកចិត្តដល់ការអនុវត្តជាក់ស្តែងដោយមានការចូលរួមពីដៃគូរដូចជា GIZ, KFW, UNDP ឬអង្គការម្ចាស់ជំនួយដទៃទៀត និងដើម្បីពង្រីកលទ្ធផលនៃគម្រោងរបស់យើងទៅកាន់ទីក្រុងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។

## ទិដ្ឋភាពទូទៅនៃសម្ព័ន្ធគម្រោង

យើងបានប្រមូលក្រុមដែលមានចំណេះ និងជំនាញអន្តរវិស័យ មានប្រវត្តិសិក្សាល្អ មានជំនាញទូលំទូលាយថ្នាក់តំបន់ និងមានបទពិសោធន៍យូរឆ្នាំលើការងារគម្រោងស្រាវជ្រាវ។

***Local Project Management Partner***
*Cambodian Institute of Urban Studies*
*General Director: Tep Makathy*
*Project Coordinator: Mach Tola*

CIUS
CAMBODIAN INSTITUTE FOR URBAN STUDIES
ទិដ្ឋភាពទូទៅនៃសម្ព័ន្ធគម្រោង

***Work Package 1: Behaviour Change***
*Leaders: Dr. Anke Blöbaum / Prof. Dr. Ellen Matthies*
*Research Associate: Annalena Becker*

OTTO VON GUERICKE UNIVERSITÄT MAGDEBURG

***Work Package 2: Sustainable Building***
*Leader: Dr. Dirk Schwede*
*Research Associate: Christina Karagianni*

University of Stuttgart
Germany

***Work Package 3: Sustainable Neighbourhoods***
*Leader: Rolf Messerschmidt*
*Research Associates: Marcelo R. Leyton & Oliver Lambrecht*

EBLE MESSERSCHMIDT PARTNER
Architekten und Stadtplaner PartGmbB

***Work Package 4: Urban Green***
*Leader: Prof. Dr. Jan-Peter Mund*
*Research Associate: Amelie McKenna*

Eberswalde University for Sustainable Development

***Work Package 5: Urban Climate***
*Leaders: Prof. Dr. Lutz Katzschner / Sebastian Kupski*

INKEK Institut für Klima- und Energiekonzepte

***Work Package 6: Sustainable Urban Transformation***
*Leader: Dr. Michael Waibel*
*Research Associate: Ravi Jayaweera*

Universität Hamburg
DER FORSCHUNG | DER LEHRE | DER BILDUNG

## BUILD4PEOPLE COORDINATION

University of Hamburg / Department of Earth Sciences
Institute of Geography / Division of Human Geography
Consortium Leader & Coordination: Dr Michael Waibel
Bundesstraße 55, 20146 Hamburg, Germany
Email: michael@build4people.org

Local Project Coordination Support: Dr Susanne Bodach
Email: susanne@build4people.org / Tel.: +855-128.56.174

*Build4People @Social Media*

Text, design & picture credits: © Michael Waibel. Language Editing: Monique Gross. Last update: 09/2019.

# Build4People Project

"លំនៅដ្ឋានដែលមានចីរភាពសម្រាប់ប្រជាជន-បង្កើនគុណភាពរស់នៅក្នុងទីក្រុងនៃប្រទេសកម្ពុជា"

www.build4people.org

*„The battle for a more sustainable future will be won or lost in cities"*
2012 Manifesto for Cities, Global Mayors' Forum

PROJECT LEADER
Universität Hamburg
DER FORSCHUNG | DER LEHRE | DER BILDUNG

SPONSORED BY THE
Federal Ministry of Education and Research

INSPIRED BY
11 SUSTAINABLE CITIES AND COMMUNITIES

## BUILD4PEOPLE WORK PACKAGES




## OVERVIEW: PRINCIPLES & AIMS OF THE BUILD4PEOPLE PROJECT

### GENERAL RESEARCH GUIDING PRINCIPLES

*action research* — *locally adapted solutions* — *demand-driven*

*balanced mix of bottom-up & top-down* — *inclusive* — *convincing people*

*dissemination & impact management* — *multi-stakeholder coalitions* — *advocacy*

### EXPECTED FINAL RESULTS / SELECT IMPACTS

*eco-city model pilot project* — *sustainable buildings* — *pro-environmental behaviour*

*green school* — *capacity building* — *mass effects through replication*

*DGNB certification* — *adapted policies and standards* — *urban quality of life city index*

### RESEARCH PARTNERS

### IMPLEMENTATION PARTNERS

### DISSEMINATION PARTNERS

## សនិទាន និងសេចក្តីផ្តើម

កាលពីមុនតាមប្រពៃណីដ៏យូរលង់ណាស់មកហើយនៅប្រទេសកម្ពុជា ស្ថាបត្យកម្មតែងតែងធ្វើការចាប់ផ្តើមគិតគូរដំបូងដោយរួមបញ្ចូល ឬផ្អែកលើលក្ខខណ្ឌអាកាសធាតុ។ ប៉ុន្តែ បច្ចុប្បន្ន គឺមានមនុស្សតិចតួចតែប៉ុណ្ណោះដែលមានចំណេះដឹង និងការយល់ដឹងលើទស្សនៈទាននេះសម្រាប់កសាងអគារប្រកបដោយចីរភាព។

ការអភិវឌ្ឍឆ្ពោះទៅរកសង្គមអ្នកប្រើប្រាស់តាមបែបទំនើប គឺបង្កើនឱ្យមានតម្រូវការប្រើប្រាស់ធនធានកាន់តែច្រើនតាមរបៀបនៃការរស់នៅរបស់បុគ្គលម្នាក់ៗ ហើយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិធីដែលអគារត្រូវបានរចនា សាងសង់ និងដំណើរការ។ ជាលទ្ធផល ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ បានកើនឡើងយ៉ាងគំហុកក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ការវិនិយោគលើប្រសិទ្ធភាពថាមពល ធានាបាននូវលទ្ធផលប្រសើរលើការវិនិយោគ ពីព្រោះតម្លៃអគ្គិសនីនៅកម្ពុជា មានតម្លៃខ្ពស់បើធៀបទៅនឹងបណ្តាប្រទេសមួយចំនួនក្នុងតំបន់។ ការកែលម្អទៅប្រើប្រាស់ប្រសិទ្ធភាពថាមពល នឹងជួយកាត់បន្ថយការពឹងផ្អែកលើការនាំចូលថាមពល ហើយវានឹងបង្កើនភាពប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

## ភាពដើម

និរន្តរភាពគឺជាបញ្ហាការផ្លាស់ប្តូរ។ ដើម្បីសម្រេចបាននូវការអនុវត្តប្រកបដោយប្រសិទ្ធិភាព និងចីរភាព យើងត្រូវអនុវត្តវិធីសាស្ត្រអន្តរវិស័យឆ្លងដែន និងវិធីសាស្ត្រដែលមានភាពច្នៃប្រឌិត និងរួមបញ្ចូលគ្នាពីវិស័យផ្សេងៗ (សូមមើលខាងលើ)។

ក្រុមការងារតាមកញ្ចប់ការងារនីមួយៗ នឹងសហការគ្នា ចែករំលែកលទ្ធផលរបស់ពួកគេ និងអភិវឌ្ឍលទ្ធផលរួមគ្នា។ ឧបករណ៍ និងផលិតផល នឹងត្រូវបង្កើតឡើងជាលក្ខណៈប្រព័ន្ធពឹងផ្អែកគ្នាទៅវិញទៅមក។ ខ្សែកោងរៀង និងការផ្តល់មតិបំពេញបន្ថែម នឹងត្រូវបានបញ្ចូលទៅក្នុងការរចនាគម្រោង។

ការលើកកម្ពស់អគារប្រកបដោយនិរន្តរភាព មិនអាចកើតឡើងបានទេតាមយុទ្ធសាស្ត្រពីលើចុះក្រោមពិសេសពាក់ព័ន្ធទៅនឹងច្បាប់ប្បញ្ញត្តិ។ ដូចនេះ ដើម្បីចាប់ផ្តើមផ្លាស់ប្តូរ និងតស៊ូមតិការអនុវត្ត យើងត្រូវអនុវត្តតាមវិធីសាស្ត្ររួមបញ្ចូលគ្នាតាមរយៈការបញ្ចូល លើកទឹកចិត្ត ផ្តល់ភាពអាចអនុវត្តបាន និងធ្វើជាគំរូ។ ក្នុងបរិបទនេះ វិធីសាស្ត្ររបស់ យើង គឺមានលក្ខណៈបញ្ចុះបញ្ចូលច្រើនជាងការបង្ខំ។

## គោលបំណងទូទៅ

គម្រោងរបស់យើង លើកកម្ពស់ អគារប្រកបដោយចីរភាព និង ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព ពីទស្សនៈមនុស្សនៅកណ្តាល (people-centred perspective) នៅក្នុងប្រទេសកម្ពុជា។ ហេតុនេះ ការផ្សារភ្ជាប់គ្នារវាងវិទ្យាសាស្ត្រ-ការគិតគូរវិភាគ និងការគិតអំពីបទដ្ឋាន ជានិច្ចកាលតែជាគុណភាពទីក្រុង។

ជាមួយនឹងគម្រោងនេះ ក្រុមពហុជំនាញរបស់យើង ផ្តោតសំខាន់លើតម្រូវការ និងសេចក្តីប្រាថ្នារបស់មនុស្ស និងធ្វើយ៉ាងណាបំពេញតម្រូវការនិងសេចក្តីប្រថ្នាទាំនេះ ដើម្បីផ្តល់ផលចំណេញ និងលើកកម្ពស់ការរស់នៅរបស់ពួកគេ។ យើង ជឿជាក់ថា កត្តានេះនឹងធ្វើឱ្យមានផលប៉ះពាល់ខ្លាំងដល់និរន្តរភាពទីក្រុងតាមរយៈកំនើនប្រើប្រាស់ថាមពល និងធនធាននៅក្នុងអគារ។ លទ្ធផលដែលពួកយើងចង់បាន គឺមិនមានអ្វីក្រៅពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងឧស្ម័នពុល ហើយជំនួសមកវិញដោយបង្កើនភាពបៃតង និងបរិយាកាសទីក្រុងប្រកបដោយផាសុខភាព លើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចចិត្ត ការកែប្រែឥរិយាបទរបស់ប្រជាជន និងការធ្វើឱ្យប្រសើរឡើងលើគុណភាពនៃជីវិតទីក្រុង។

ក្រុមប្រឹក្សាពិគ្រោះយោបល់របស់យើង នឹងធានាថាវិធានការរបស់យើង គឺផ្អែកលើតម្រូវការ និងសម្របតាមបរិបទក្នុងតំបន់។